# អ្នកនាំសារ

The Messenger


# វិស្សមកាលៈ មិនស្គាល់ !

ប្រជាជនដែលមានកម្រិតជីវភាពគ្រប់គ្រាន់ វិស្សមកាលមានន័យស្មើនឹងការសម្រាកលំហែកាយ។ ប៉ុន្តែ វិស្សមកាលមិនមែនជាពេលមួយដ៏ប្រសើរសម្រាប់សម្រាកដោយមិនធ្វើអ្វីសោះនោះទេ វាជាពេលវេលាមួយ គួរស្វែងយល់ចំណេះដឹងទូទៅនៅតាមកន្លែងផ្សេងៗដែលបានទស្សនាកំសាន្ត ដើម្បីអភិវឌ្ឍខ្លួនផងដែរ។

លោក លី សុខថន បានធ្វើការចាប់អារម្មណ៍ ពេលទស្សនាកំសាន្តឧទ្យានទឹក **Water Park** ថា “ជាការល្អណាស់ ដែលគេរៀបចំទីកន្លែងកំសាន្តលំហែជិតៗរបៀបនេះ ដោយមិនបាច់ចំណាយពេលច្រើនក្នុងការធ្វើដំណើរ និងមានកន្លែងច្រើនសំរាប់លេងដូចជា ជិះពោងរំអិល”។ ចំណែក ប៊ុន ធឿន និស្សិតផ្នែកវេជ្ជសាស្ត្រ បានឱ្យដឹងដែរថាៈ “ខ្ញុំបានទៅសួនសន្តិភាព ទីនោះគេរៀបចំលក្ខណៈធម្មជាតិ មានកន្លែងសំរាកច្រើន និងកន្លែងហែលទឹកប្រកបដោយផាសុខភាព”។ តទៅទំព័រទី៤



Water Park: មាត់សមុទ្រក្នុងទីក្រុង

Photo Xavier Huchet

## សន្និសីទជាសកលលើកទី ១៥ ស្ដីអំពីជំងឺអេដស៍ នៅបាងកក ប្រទេសថៃ



Photo D.R

លោក កូហ្វី អាណាន់

លោកកូហ្វីអាណាន់ បានរំលឹករដ្ឋាភិបាលនានាពីកិច្ចសន្យារបស់ពួកគេ។ ក្នុងពេលនៃការប្រព្រឹត្តទៅនៃសន្និសីទចុងក្រោយ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានចាត់ទុកថាៈ “លទ្ធផលដែលទទួលបាន គឺវាមិនទាន់គ្រប់គ្រាន់”។

ថ្វីបើការរំលឹកនេះសំដៅចំពោះអ្នកនយោបាយដែលបានចុះកិច្ចសន្យារបស់ខ្លួន ក៏លោកមិនសំចៃចំពោះសង្គមស៊ីវិលផងដែរ។ គំនិតផ្តួចផ្តើមមិនគួរចេញតែពីអ្នកមានអំណាចតែម្ខាងប៉ុណ្ណោះនោះទេ។ ស្ត្រីពេញវ័យចំនួនជិតពាក់កណ្តាលបានធ្លាក់ខ្លួនឈឺ នៅក្នុងពិភពលោកនាបច្ចុប្បន្ននេះ។ នៅចុងឆ្នាំ ២០០៣ អង្គការសហប្រជាជាតិប៉ាន់ស្មានថា មានមនុស្ស ៤០ លាននាក់ បានឆ្លងជំងឺអេដស៍។

# យុវជនខ្មែរក្នុងយុគសម័យព័ត៌មា



Photos D.R

ប្រទេសកម្ពុជា ជាប្រទេសដែលស្ថិតនៅក្នុងចំណោមប្រទេសក្រីក្រ និងកំពុងអភិវឌ្ឍន៍ក្នុងពិភពលោក។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងទទួលឥទ្ធិពលយ៉ាងខ្លាំងពីបច្ចេកវិទ្យាទំនើបៗនៃប្រព័ន្ធផ្សព្វផ្សាយយុគព័ត៌មាន ពីបណ្តាប្រទេសអភិវឌ្ឍន៍នានានៅលើពិភពលោក មានដូចជា ប្រទេសជប៉ុន សហរដ្ឋអាមេរិក និងបណ្តាប្រទេសនៃសហភាពអឺរ៉ុបមួយចំនួនទៀតផង។ នៅក្នុងប្រទេសយើង គេឃើញមានយុវជនយុវនារីជាច្រើន កំពុងប្រើប្រាស់បច្ចេកវិទ្យាទំនើបនេះ ជាមូលហេតុនាំឱ្យមានការផ្លាស់ប្តូរទំនៀមទម្លាប់ ប្រពៃណីដ៏ថ្លៃថ្នូររបស់ខ្លួនផងដែរ តាមរយៈការហូរចូលនូវប្រព័ន្ធផ្សព្វផ្សាយនានាដូចជា វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី តន្ត្រីសម័យទំនើប ប្រព័ន្ធអិនធឺណែត និងបច្ចេកវិទ្យាទំនើបៗផ្សេងៗទៀត។ យើងជាយុវជនខ្មែរ គួរតែដឹងឱ្យច្បាស់ នូវការជះឥទ្ធិពលដ៏ខ្លាំងក្លានេះដែលកំពុងតែវាយលុក ចូលមកក្នុងចិត្តគំនិតនិងរកផ្លូវទន្ទ្រាន ចូលក្នុងប្រពៃណី វប្បធម៌ដ៏ផូរផង់របស់យើងផងដែរ។ ប្រសិនបើយុវជនយុវនារី មិនអើពើ មិនយកចិត្តទុកដាក់ ឬមិនចាប់អារម្មណ៍អំពីបញ្ហានេះទេនោះ ក្នុងពេលឆាប់ៗនេះ យើងនឹងបាត់បង់នូវអរិយធម៌ ដែលជាអត្តសញ្ញាណជាតិ ជាពលរដ្ឋខ្មែរ ជាក់ជាមិនខានឡើយ។ ម្យ៉ាងទៀត យើងនឹងក្លាយជាជនរងគ្រោះដោយ មិនដឹងខ្លួនពីយុគព័ត៌មានទំនើបនេះ។



## ទស្សនាវដ្តីធ្វើឱ្យយុវជនរំភើបអារម្មណ៍

ទស្សនាវដ្តីមានសារៈសំខាន់ណាស់នៅក្នុងប្រទេសនីមួយៗ ដោយសារទស្សនាវដ្តីបានបង្ហាញគំនិតដ៏ច្រើនក្នុងសង្គម។ ទស្សនាវដ្តីដែលល្បីជាងគេ គឺទស្សនាវដ្តីដែលនិយាយអំពីសិល្បករ បវរកញ្ញា និងការបង្ហាញម៉ូដ ដូចជាសក់ សំលៀកបំពាក់ ប្រដាប់ប្រដាប្រើប្រាស់ផ្សេងៗ។ នៅកម្ពុជា មានទស្សនាវដ្តីជាច្រើនបានចេញផ្សាយ មានជាអាទិ៍ ប្រជាប្រិយ ជំទង់រីករាយ ឥន្ទ្រទេវី សម័យថ្មី អង្គរធំ ប្រជានុភាព វិទ្យាសាស្ត្រកំព្យូទ័រ ទីក្រុងពត៌មានវិទ្យា និងទស្សនាវដ្តីកូលាប។ ក្នុងចំណោមទស្សនាវដ្តីទាំងនោះ អ្នកអាននិយមតាមការចូលចិត្តរបស់គេម្នាក់ៗ។ សិស្ស និស្សិតតាមវិទ្យាល័យមហាវិទ្យាល័យ ឬវិទ្យាស្ថាន ចូលចិត្តទស្សនាវដ្តីស្តីពីវិទ្យាសាស្ត្រកុំព្យូទ័រ និងព័ត៌មានវិទ្យា ពីព្រោះជាប្រភេទទស្សនាវដ្តី និយាយពីការបង្រៀនការជួសជុលកុំព្យូទ័រ និងពីអ្វីដែលទាក់ទងនឹងកុំព្យូទ័រតែម្តង។ ចំណែកឯបុគ្គលិក មន្ត្រី នៅតាមក្រសួង ស្ថាប័នមួយចំនួន ចូលចិត្តទស្សនាវដ្តីប្រជាប្រិយ ឥន្ទ្រទេវី ព្រោះគេចូលចិត្តចង់ដឹងពីហេតុការណ៍ពិសេស ដែលកើតមាននៅក្នុងប្រទេស អំពីតារាភាពយន្ត និងតារាចំរៀងជាដើម។ ចំណែកទស្សនាវដ្តី ជំទង់រីករាយ អង្គរធំ ភាគច្រើនយុវជនយុវតីចូលចិត្តអាន។ ជាប្រភេទទស្សនាវដ្តីមួយដែលលក់ដាច់ជាងគេ ក្នុងមួយខែៗពី ២៥-៣០ ច្បាប់។

### ខារ៉ាអូខេ

លោក រិទ្ធិ ជានិស្សិតច្បាប់ បានបង្ហាញចំណាប់អារម្មណ៍ថា “ ខ្ញុំចូលចិត្តអ្នកចម្រៀង ព្រាប សុវត្ថិ គឹម លក្ខិណា និងម៉េង កែវពេជ្ជតា ព្រោះពួកគាត់មានសំលេងពីរោះ។ ចំពោះបទចម្រៀងសម័យមុន ខ្ញុំក៏នៅមិនភ្លេចដែរ និងនៅតែមានការគាំទ្រ ទោះបីសម័យនេះ ជាសម័យទំនើបក៏ដោយ។ ខ្ញុំចូលចិត្តច្រៀងខារ៉ាអូខេ នៅពេលឈប់សម្រាកពីការងារ ហើយទៅច្រៀងនៅជិតផ្ទះរបស់ខ្ញុំ ជាមួយមិត្តភក្តិ។ តម្លៃច្រៀងក្នុងមួយម៉ោង ៥០០០ រៀល ” ។

# ទំនើប

## កុនខ្មែរ “មរណមាតា”




**នេះ**ជាកុនខ្មែរមួយ ដែលប្រជាជនមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ តើមានមូលហេតុអ្វីដែលធ្វើឱ្យគេចូលចិត្ត?

បងស្រី ឃូ ឡាឌី បាននិយាយថា “ ពីមុនខ្ញុំមិនដែលមើលកុនទេ នេះជាលើកទីមួយហើយសម្រាប់ខ្ញុំ។ ខ្ញុំចាប់អារម្មណ៍រឿងមរណមាតា ដោយសារវាបង្ហាញពីឈុតឆាកកំសត់ៗ និងតក់ស្លុត។ ភាពយន្តនេះ ជារឿងបុរាណរបស់ខ្មែរ យើងជាខ្មែរត្រូវនាំគ្នាគាំទ្រវប្បធម៌ជាតិ។ ចំណែកអ្នកមីងម្នាក់ទៀតបានមានប្រសាសន៍ថា “ខ្ញុំមើលរឿងមរណមាតា ព្រោះជារឿងប្រពៃណីខ្មែរពីដើម និងចង់មើលពីសមត្ថភាពសំដែងរបស់ក្មេងៗជំនាន់ក្រោយ។ រឿងខ្មែរនិងរឿងបរទេស ខ្ញុំចូលចិត្តរឿងខ្មែរ ខ្ញុំយល់ថា “ ខ្ញុំជាខ្មែរត្រូវគាំទ្រខ្មែរ” ។

លោក គង់ ចន្ថា ជាម្ចាស់ផលិតកម្មមានប្រសាសន៍ថា “រឿងមរណមាតានេះក៏បង្ហាញតថភាពពិតៗរបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងសង្គមសព្វថ្ងៃនេះផងដែរ ដូចជា ម្ដាយចុងធ្វើបាបកូនដើម និងឈុតមួយចំនួនទៀត។ បើប្រៀបធៀបខ្សែភាពយន្តខ្មែរ និងភាពយន្តបរទេស គឺអ្នកទស្សនាចូលចិត្ត និងគាំទ្រភាពយន្តខ្មែរច្រើនជាង។ ចំពោះយុវវ័យជនដែលចូលចិត្តមើលខ្សែភាពយន្តនោះ គឺមិនមែនសំខាន់ទៅលើសាច់រឿងទេ គឺឱ្យតែរឿងល្អពួកគេចូលចិត្តទាំងអស់ ”។

## ភូមិសកល ( The global village )



នេះជាមូលហេតុ ដែលពិភពលោកសព្វថ្ងៃប្រៀបដូចជា ភូមិតូច មួយដែលយើងហៅថា “ភូមិសកល” មានន័យថា បើមានហេតុការណ៍អ្វីតូចមួយកើតឡើង នៅកន្លែងណា នឹងលេចឮភ្លាមៗនៅក្នុងពិភពលោកទាំងមូល។ តាមមធ្យោបាយផ្សេងៗ នៃបច្ចេកវិទ្យាសម័យទំនើប ជាពិសេសគឺ “អិនធឺណែត”។ វាជាប្រភពផ្ដល់ព័ត៌មានយ៉ាងលឿនបំផុត ប្រៀបដូចជា ហេតុការណ៍នោះ ជាការខ្សឹបខ្សៀវគ្នានៅក្នុងភូមិដ៏តូចមួយ។ យើងជាយុវជន ត្រូវតែរៀបចំខ្លួនឱ្យបានល្អ និងរៀនសូត្រនូវបច្ចេកវិទ្យាទំនើបទាំងនេះ ដើម្បីយកទៅបម្រើប្រទេសជាតិ អោយងើបចេញពីភាពក្រីក្រ។

លោកឪពុក អូមែរ



## អំពីវិទ្យុ

តាមសំដីរបស់យុវនារីម្នាក់បាននិយាយថា “ នាងចូលចិត្តស្ដាប់វិទ្យុ FM 98 MHz និងមិនចូលចិត្តវិទ្យុ FM 97 MHz ទេ។ កម្មវិធីដែលចូលចិត្តមាន មេផ្ទះ សុជីវធម៌ ការរៀបចំខ្លួន ពត៌មានថ្មីៗ បទចម្រៀងមនោសញ្ចេតនា។

យុវនារីម្នាក់ទៀតបានឱ្យដឹងថា: នាងចូលចិត្តស្ដាប់វិទ្យុ FM 98 MHz និង FM 103 MHz ពីព្រោះវិទ្យុនេះដំណើរការ ២៤ ម៉ោង លើ ២៤ ម៉ោង នៅក្នុងកម្មវិធីនយោបាយ និងការនិយាយឆ្លើយឆ្លងតាមទូរស័ព្ទ កម្មវិធីនិយាយអំពីលទ្ធិប្រជាធិបតេយ្យ និងកម្មវិធីទាក់ទងនឹងការប្រើអំពើហិង្សា។

យុវជនម្នាក់ទៀតបាននិយាយថា “លោកចូលចិត្តស្ដាប់វិទ្យុ FM 105 និង FM 103 MHz ពីព្រោះមានពិធីករល្អៗ និយាយពីរោះ ពួកគេនិយាយធ្វើឱ្យលោកឆាប់យល់ មានពត៌មានល្អៗ និងបទចម្រៀងពីរោះៗ។

# វិស្សមកាល...

ផ្ទុយទៅវិញ ចំពោះបងប្អូនមួយចំនួនទៀត វិស្សមកាលជារយៈពេលនៃសកម្មភាពដ៏មមាញឹកទៅវិញ។ អ្នកមីង គីម ឈេង អាយុ ៤៨ ឆ្នាំ និងស្វាមីឈ្មោះ ឃឿន គីមហ៊ុម រស់នៅភូមិសន្សំកុសល ក្រុម ៦ សង្កាត់បឹងទំពុន។ អ្នកមីងបានមានប្រសាសន៍ថា ”អ្នកមីងនិងក្រុមគ្រួសារ មិនដែលបានដើរកំសាន្តទៅទីណាទេ ហើយចំពោះកូនៗរបស់គាត់ ពេលវិស្សមកាលម្តងៗ ពួកគេតែងតែចេញទៅរកកម្រៃ ដើម្បីយកមករៀនគួរបន្ថែម”។ អ្នកមីងនិងគ្រួសារ ចង់ឱ្យកូនៗទៅលេងកំសាន្តកន្លែងផ្សេងៗណាស់ តែគាត់ខ្វះសមត្ថភាព ព្រោះសព្វថ្ងៃអ្នកមីងគ្រាន់ តែជាអ្នកលក់បន្លែបន្តិចបន្តួចតែប៉ុណ្ណោះ។

ចំណែកអ្នកមីង ជា ស៊ីថា រស់នៅភូមិក្បាលទំនប់ ក្រុម ៤៤ សង្កាត់បឹងទំពុន អ្នកមីងនិងគ្រួសារជាកម្មករសំណង់ ក៏បានបញ្ជាក់ឱ្យដឹងថា “សម្រាប់គ្រួសាររបស់ខ្ញុំ មិនដែលមានពេលទំនេរសម្រាប់វិសម្សកាលទេ ហើយនៅពេលមានបុណ្យទានម្តងៗ យើងបានទៅមើលគេ ព្រមទាំងផ្ញើរបស់របរយកទៅលក់”។ កុមារី កែប សុខរី ជាសិស្សថ្នាក់ទី ៦ និងជាកូនស្រីរបស់អ្នកមីងក៏បានបន្ថែមថា ”ពេលទំនេរ ខ្ញុំនៅផ្ទះមើលប្អូន និងលេងជាមួយក្មេងៗជិតខាង”។ រីឯលោកស្រី ប៉ែន សំអុល ដែល ជាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល អ្នកស្រីមានកូន ៦ នាក់ កូនខ្លះគេរៀបការរួចហើយ។ នៅពេលទំនេរជួនកាលកូនរបស់គាត់ទៅដើរកំសាន្តជាមួយមិត្តរបស់គេ ហើយចំណែកការធ្វើដំណើរកំសាន្តជាគ្រួសារវិញ មិនដែលទៅរួមគ្នាទាំងអស់ទេ។ នៅពេលវិស្សមកាលនេះ កូនរបស់ខ្ញុំបានសុំខ្ញុំទៅលេងសៀមរាប។


អ្នកមីង គីម ឈេងនិងកូនៗ

> “ខ្ញុំមានសេចក្តីអំណររីករាយណាស់ ដែលបាននាំកូនមកស្គាល់ស្រុកកំណើតរបស់ខ្ញុំដូច្នេះ”។

នេះជាសំដីរបស់លោក សារិន ជាអនិកជនខ្មែរ រស់នៅស្រុកបារាំង បានមកលេងស្រុកកំណើតជាមួយក្រុមគ្រួសារ និងដើរកំសាន្តនៅកន្លែងផ្សេងៗ។ នៅប្រទេសបារាំងខ្ញុំចូលចិត្តទៅលេងនៅតាមភ្នំ មាត់សមុទ្រជាមួយគ្រួសារ ទៅសួរសុខទុក្ខមិត្តភក្តិនិងបងប្អូន។ លោកមានប្រសាសន៍បន្តថា ” ពេលខ្ញុំនិងគ្រួសារធ្វើដំណើរទៅ

---


យុវសិស្ស អ៊ូ គុណលី ទៅកំសាន្តនៅមាត់សមុទ្រ

# ពេលវេលាដ៏ល្អសម្រាប់យើង

វិសម្សកាលជា ពេលវេលាដ៏ល្អមួយសម្រាប់យើងទាំងអស់គ្នា ដើម្បីបំបាត់នូវអារម្មណ៍តានតឹង នៅក្នុងការងារ ក្នុងការសិក្សា។

កញ្ញា វ៉ាន់ ហាន់ ជាសិស្សនៃវិទ្យាល័យទួលទំពូង បានរៀបរាប់អំពីសម្មភាពរបស់គេ នៅពេលវិសម្សកាលថា ”ពេលខ្ញុំមានពេលទំនេរខ្ញុំជាមួយនិងមិត្តរួមថ្នាក់ តែងទៅដើរកំសាន្តនៅតាមកន្លែងផ្សេងៗ។

ក្រៅពីការដើរកំសាន្ត ខ្ញុំបានជួយកិច្ចការផ្ទះនិងទៅរៀនគួរបន្ថែម“។ ចំណែកឯយុវសិស្ស អ៊ូ គុណលី ជាសិស្សថ្នាក់ ទី ១១ វិទ្យាល័យវត្តកោះនាងបាននិយាយថា: ”ពេលវិសម្សកាលនាងចូលចិត្តទៅលេងមាត់សមុទ្រតែម្នាក់ឯងព្រោះចង់នៅស្ងៀមស្ងាត់ ហើយនឹងទៅខេត្តផ្សេងៗ ទៅជួយបងស្រីអប់រំជំនឿក្មេងៗ ទៅសួរសុខទុក្ខអ្នកជម្ងឺ ជាពិសេសនាងចូលចិត្តទៅតាមខេត្តជិះកង់ដើរលេង”។ កញ្ញា ញឹក ស្រីវ៉ាន់ បានឱ្យដឹងដែរថា ”នៅក្នុងគ្រួសារខ្ញុំនៅពេលមានវិសម្សកាល ម៉ាក់ប៉ាតែងតែនាំកូនៗទៅដើរលេង ប៉ុន្តែ ខ្ញុំមិនសូវបានទៅលេងជាមួយគ្រួសារទេ ភាគច្រើនខ្ញុំទៅជាមួយមិត្តភក្តិ អ្វីដែលខ្ញុំចូលចិត្តជាងគេនោះ គឺទស្សនារមនីយដ្ឋានប្រវត្តិសាស្ត្រ។ យុវវ័យខ្លះធ្វើដំណើរទៅកន្លែងផ្សេងៗ ដើម្បីសម្រាកជាក្រុម ម្នាក់ឯង ឬជាមួយគ្រួសារផងដែរ។

សំ អាត



កំពត ខ្ញុំបានទៅចំណតរថយន្ត ពេលមានគេមកទាញយកកាបូបចូលតាក់ស៊ី ធ្វើឱ្យកូនៗរបស់ខ្ញុំមានការភ័យខ្លាច ដោយគេមិនធ្លាប់ជួបបែបនេះពីមុនមក"។ មុនពេលលោកមកលេងស្រុកកំណើត លោកត្រូវសន្សំថវិកា ៤ ឆ្នាំ។ កាធ្វើដំណើរកំសាន្តបានគ្រប់ទីកន្លែង អាស្រ័យលើថវិកា។

ចំណែកលោក មុំ ពិសិដ្ឋ ជាជនជាតិខ្មែរនៅអាមេរិកដែរ។ លោកតែងមកលេងស្រុកទេសមួយឆ្នាំម្តង។ លោកមានស្រុកកំណើតនៅខេត្តបាត់ដំបង។ លោកមកតែម្នាក់ឯងទេ ដើម្បីសួរសុខទុក្ខបងប្អូននៅស្រុកកំណើត លោកមានសេចក្តីសប្បាយរីករាយណាស់ ដោយបានឃើញថា ឥឡូវនេះមានការបង្កើតកន្លែងថ្មីៗជាច្រើនសម្រាប់កំសាន្ត ទោះបីមិនទាន់ដូចនៅបរទេស ប៉ុន្តែយើងមានការរីកចម្រើនជាងមុន។ នៅឯអាមេរិកវិញពេលវិសម្សកាល គាត់តែងនាំកូនទៅកំសាន្តនៅតាមរដ្ឋផ្សេងៗ ជួនកាលទៅសួរសុខទុក្ខមិត្តភក្តិ ទៅលេងសមុទ្រ ឬឡើងភ្នំនាពេលសម្រាកពីការងារ។

សំ អាត

## តើលោកអ្នកចូលចិត្តកន្លែងណា?

**សារមន្ទីរជាតិ:** បើកទទួលភ្ញៀវពីថ្ងៃចន្ទ័ ដល់ថ្ងៃអាទិត្យ វេលាម៉ោង ៨.០០ ព្រឹក ដល់ម៉ោង ៥.០០ រសៀល។ សំបុត្រចូលទស្សនាសម្រាប់ភ្ញៀវជាតិម្នាក់ ៥០០ រៀល និងភ្ញៀវបរទេសម្នាក់ ៣ ដុល្លា។

**ចាវ៉ាកាហ្វេ (Java café):** ផ្ទះលេខ ៥៦ E1 តាមផ្លូវព្រះសីហនុ ជាប់សួនច្បារវិមានឯករាជ្យ ជាហាងកាហ្វេបរទេស និងមានដាក់តាំងពិព័រណ៍ស្នាដៃផ្សេងៗ (មួយខែដូពីព័រណ៍ម្តង)។

**ផាមធួរ (PalmTours):** ជាសេវាកម្មសម្រាប់ដំណើរកំសាន្ត ដែលមានការស្នាក់នៅ អាហារថ្ងៃត្រង់-ល្ងាច សំបុត្រតាមកម្មវិធី និងមគ្គុទ្ទេសក៏។
ថ្ងៃទី ២៧-២៩ សីហា: កោះកុង ម្នាក់ ៥០ ដុល្លា។
ថ្ងៃទី ១១-១២ កញ្ញា: (កម្មវិធីពិសេស): ពោធិ៍សាត់ ១៩ ដុល្លាម្នាក់ គ្រប់ដំណើរកំសាន្ត ឈប់ទទួលប្រាក់ ៧ ថ្ងៃមុនពេលចេញដំណើរ។
ទូរសព្ទ័លេខ: (០១២) ៦៦៦ ២៧៨

**រោងល្ខោនសាលាភូមិន្ទវិចិត្រសិល្បៈ:** (ជិតស្តាតចាស់) នៅថ្ងៃទី ២៦ សីហា ២០០៤ ទស្សនីយភាពល្ខោនបាសាក់។

**វិទ្យាស្ថានសិល្បៈ និងវប្បធម៌ (រ៉ៃយ៉ំ):** ជាអង្គការក្រៅរដ្ឋាភិបាលបម្រើផ្នែកសិល្បៈនិងវប្បធម៌ខ្មែរ តាមរយៈពិព័រណ៍ និងបោះពុម្ពសៀវភៅជាដើម។ ទទួលភ្ញៀវ ថ្ងៃចន្ទ័-អាទិត្យ ពីម៉ោង ៨-៦.៣០ ល្ងាច។

**ខែសីហា ២០០៤** ពិព័រណ៍អ៊ី **ព្រលឹងវិញ្ញាណ**។

សុវណ្ណា

## យុវនារីបីនាក់ ទៅតេហ្សេ

តេហ្សេ ជាសហគមន៏គ្រិស្តសាសនាមួយនៅប្រទេសបារាំង។ យើងស្គាល់សហគមន៏នេះតាមរយៈការរៀបចំអធិដ្ឋានដោយមានច្រៀងចម្រៀងខ្លីៗ ដកស្រងចេញពីព្រះគម្ពីរ ធ្វើឱ្យការអធិដ្ឋានបានស៊ីជំរៅចូលក្នុងអត្ថន័យព្រះគម្ពីរ។ សហគមន៏នេះមានទំនាក់ទំនងជាមួយព្រះសហគមន៏នៅកម្ពុជាយូរមកហើយ។ រៀងរាល់ឆ្នាំ សហគមន៏បានទទួលយុវជន យុវនារីកម្ពុជា ឱ្យចូលរួមសកម្មភាពផ្សេងៗរបស់សហគមន៏។ នៅឆ្នាំនេះ មានយុវនារីបីនាក់ទៅទីនោះរយៈពេលពីរខែកន្លះ មានបង សុជាតិ ជុំ ចន្ធូ និង ដាលីស។ កញ្ញា ចន្ធូ បង្ហាញពីអារម្មណ៏របស់ខ្លួនថា "ខ្ញុំមានអំណរសប្បាយណាស់ ដែលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំទៅកន្លែងមួយ ដែលខ្ញុំមិនស្គាល់"។ កញ្ញា ដាលីស បានបន្តថា "នេះជាឱកាសមួយដ៏ល្អសម្រាប់យុវជនខ្មែរ ដើម្បីជួបយុវជនប្រទេសផ្សេងៗទៀត ជាពិសេសនៅទីនោះ មានការអធិដ្ឋានជាច្រើន ធ្វើឱ្យយើងខិតទៅកាន់តែជិតព្រះជាម្ចាស់ថែមទៀត"។

ចំពោះបទពិសោធន៏របស់ព្រះសហគមន៏ លោកអភិបាល អន់តួនី បានប្រាប់ថា "ដំណើរទៅតេហ្សេ មិនត្រឹមតែឱ្យមានអារម្មណ៏សប្បាយអធិដ្ឋានឱ្យមានអារម្មណ៏ស្រួល មានកិត្តិយសដែលបានបង្ហាញពីប្រទេសរបស់ខ្លួនប៉ុណ្ណោះទេ គឺធ្វើឱ្យគេមានចិត្តចូលរួមសកម្មភាពផ្សេងៗផងដែរ ព្រោះតាមរយៈសកម្មភាពរបស់សហគមន៏ បានជួយឱ្យយុវជនយើងមានសមត្ថភាពក្នុងទំនួលខុសត្រូវបានច្រើន ហើយពេលគេត្រលប់មកវិញ គេអាចជួយព្រះសហគមន៏ច្រើនដែរ នេះជាចំណុចល្អរបស់សហគមន៏តេហ្សេ"។

សុវណ្ណា

## សក្ខីភាព



# លាហើយភ្នំពេញ!

**អ្នកនាំសារៈ** ពេលអ្នកមកបាន ដល់តើអ្វីដែលមានភាពខុសគ្នាខ្លាំងរវាងប្រទេសរបស់អ្នក និងទីក្រុងភ្នំពេញ?

**Amadeus:** គឺសកម្មភាពដែលមានភាពរួសរាយរាក់ទាក់របស់ប្រជាជន។ គឺវាមានភាពងាយស្រួលក្នុងការនិយាយជាមួយមនុស្សប្លែកៗ នៅទីនេះដែលការពិតវាពិបាកណាស់នៅក្នុងប្រទេសអង់គ្លេស គឺមិនងាយស្រួល។

**Xavier:** ខ្ញុំយល់ស្រប គឺប្រជាជនជាច្រើនដែលប្រកបមុខរបរផ្សេងៗនៅតាមដងផ្លូវជារៀងរាល់ថ្ងៃ។ អ្វីដែលខុសគ្នាឆ្ងាយ គឺមុខរបររាល់ថ្ងៃនៅក្នុងទីក្រុងភ្នំពេញ ក្រោយម៉ោង ៧ យប់តាមដងវិថី គឺស្ងាត់។ ចំណែកនៅបារាំងវិញ មនុស្សចូលចិត្តដើរលេងយប់។

**អ្នកនាំសារៈ** តើអ្នកឃើញមានអ្វីប្លែកចំពោះព្រះវិហារនៅទីនេះ និងនៅអឺរ៉ុប?

**Amadeus:** ខុសគ្នាឆ្ងាយណាស់ គឺមានយុវជនៗតិចតួច ដែលទៅអភិបូជា ពីព្រោះវាមិនសូវទាន់សម័យ។ ចំណែកឯនៅទីនេះវិញ គឺមានគ្រិស្តបរិស័ទតិចតួច ប៉ុន្តែ ព្រះវិហារមានមនុស្សពេញ ហើយនិងមានសកម្មភាពរស់រវើក។

**Xavier:** បាទ! ទីនេះជាពិភពមួយផ្សេងទៀត។ នៅប្រទេសអង់គ្លេសការទៅព្រះវិហារ គឺជាកាតព្វកិច្ចចំពោះមនុស្សជាច្រើន គឺដូចជាប្រពៃណីទំនៀមទំលាប់ ដែលត្រូវធ្វើនៅថ្ងៃអាទិត្យ។ ព្រះវិហារច្រើនមានមនុស្សតិច និងមិនសូវរស់រវើកឡើយ។

**អ្នកនាំសារៈ** អ៊ីចឹង អ្នកឃើញថាគឺវាងាយស្រួលរស់នៅទីនេះជាងនៅបរទេស?

**Amadeus:** ក្នុងការទំនាក់ទំនងជាមួយមនុស្ស ពីមួយថ្ងៃទៅមួយថ្ងៃមានភាពងាយស្រួល ប៉ុន្តែ ដើម្បីឱ្យមានទំនាក់ទំនងជ្រៅជាងនេះ គឺវាពិបាក ពីព្រោះតែភាពខុសគ្នារវាងគំនិតរបស់អឺរ៉ុបនិងអាស៊ី។

**Xavier:** នៅទីនេះការរស់នៅហាក់បីដូចជាងាយស្រួលជាង ពេលណាដែលយើងមានការងារល្អ យើងអាចរកលុយបានគ្រប់គ្រាន់សំរាប់ជីវភាព ការចំណាយក៏ថោកជាងនៅអឺរ៉ុប។ ទីនេះការរស់នៅ គឺមានភាពសប្បាយច្រើន អ្នកអាចចាប់អារម្មណ៍ថា អ្នកចង់ដើរលេងរាល់ថ្ងៃ។

**អ្នកនាំសារៈ** ហេតុអ្វី?

**Xavier:** ហ៊ឺ! អាកាសធាតុល្អមនុស្សម្នាញញឹមរួសរាយរាក់ទាក់ អ្វីៗទាំងអស់គឺខុសពីអឺរ៉ុប ដូចជានៅជនបទ អាហារ បរិយាកាស គឺប្លែកកម្រឃើញ។

**អ្នកនាំសារៈ** អ៊ីចឹង! ហេតុអ្វីអ្នកមិនមកតាំងលំនៅនៅទីនេះ?

**Xavier:** ជីវិតស្រួលនៅពេលអ្នកបានសំរាកកំសាន្ត វាមិនមែនជាការពិតនោះទេ វាដូចជាក្តីស្រមៃ។ វប្បធម៌ហើយនិងឥរិយាបទ គឺខុសគ្នារវាងប្រជាជនអឺរ៉ុប និងប្រជាជនខ្មែរ។ វាគឺជារឿងល្អ ដែលត្រូវត្រឡប់ទៅប្រទេសកំណើតវិញ។

**Amadeus:** វាជាពិភពលោកមួយខុសគ្នាយ៉ាងពិតប្រាកដ ទោះបីជាទិដ្ឋភាពប្រទេស និងវប្បធម៌ល្អក៏ដោយ។ ខ្ញុំ គឺជាជនជាតិបរទេសនៅតែជាបរទេសរហូត។ រឿងរ៉ាវខ្លះៗដែលកើតឡើង យើងបញ្ចេញត្រង់ៗ តែប្រជាជននៅទីនេះ គឺស្ងៀម ដូចជានៅពេលយើងជួបបញ្ហាមួយ យើងខឹងភ្លាម ស្រែក ធ្វើការតវ៉ា ប៉ុន្តែ ប្រជាជននៅទីនេះ គឺបែរជាស្ងៀមស្ងាត់ទៅវិញ។ ម្យ៉ាងវិញទៀត បញ្ហាដែលមានភាពស្មុគស្មាញសម្រាប់អឺរ៉ុប នៅទីនេះមានភាពងាយស្រួលទៅវិញ។

**អ្នកនាំសារៈ** ចំពោះអ្នក តើអ្វីដែលល្អ ហើយនិងមិនសូវល្អនៃអត្តចរិតរបស់ប្រជាជនកម្ពុជា?

**Amadeus:** ប្រជាជនកម្ពុជា មានទឹកចិត្តទូលាយ ប្រហែលមានបំណងឱ្យជីវិតមានការសប្បាយច្រើន។

**Xavier:** ប្រជាជនខ្មែរមានសុជីវធម៌គោរពចំពោះមនុស្សចាស់ ប៉ុន្តែ ពេលខ្លះជ្រុលពេក។ ប្រជាជនខ្មែរមិនហានបញ្ចេញអារម្មណ៍ផ្ទាល់ខ្លួនពេលធ្វើអ្វីមួយខុស។ ខ្ញុំសំណូមពរឱ្យប្រជាជនខ្មែរបញ្ចេញនូវគំនិតផ្ទាល់ខ្លួនដោយក្លាហាន។

សូមអរគុណចំពោះ

សាវីយេ៉ និង អាម៉ាដេអ៊ូស

messager aout 04.qxd 2/25/2005 2:18 PM Page 7



# ការធ្វើឱ្យប្រសើរវេទនារម្មណ៍

យើងមានទាំងភាពទន់ខ្សោយ និងភាពខ្លាំង ចំណែកល្អ និងចំណែកមិនសូវល្អ។ គ្មានមនុស្សណាម្នាក់សុក្រឹតឥតខ្ចោះនោះទេ។ វាសំខាន់ក្រៃលែងបំផុតដែលយល់ដឹងថា: អ្នកជាមនុស្សល្អ ជាមនុស្សមានប្រយោជន៏ ជាមនុស្សមានសមត្ថភាពនោះ។ អ្នកគោរពមនុស្សឯទៀត។ ហើយជាញឹកញាប់ អ្នកគិតដល់គេច្រើនជាងខ្លួនអ្នក។ “ គាត់ឬនាងល្អប្រសើរជាងខ្ញុំ”។ មនុស្សខ្លះអាចធ្វើអ្វីៗមួយចំនួនបានល្អប្រសើរជាងមនុស្សដទៃ។ មិត្តអ្នកអាចលេងតេនីសបានល្អជាង ឬដាំស្លបានល្អប្រសើរជាងអ្នកដទៃ។ មនុស្សគ្រប់រូបល្អ។ គ្មាននរណាល្អប្រសើរជាងនរណាម្នាក់នោះទេ។ យើងទាំងអស់ស្មើគ្នា។ យើងទាំងអស់គ្នាជារូបតំណាងរបស់ព្រះជាម្ចាស់។ តើយើងទាំអស់មិនមានបិតាតែមួយរួមគ្នាទេឬ? តើមិនមានព្រះជាម្ចាស់តែមួយបង្កើតយើងរាល់គ្នាទេឬ?

ចូរបង្កើតបញ្ជីបង្ហាញយ៉ាងតិច ១០ ករណីដែលថា អ្នកជាមនុស្សល្អនៅលើទំព័រនេះ។ ឥឡូវនេះ អ្នកធ្វើបញ្ជីមួយទៀត ដែលបង្ហាញថា អ្នកបានធ្វើអ្វីៗល្អ។ ចូរបញ្ចូលទៅក្នុងបញ្ជីអ្វីៗដែលល្អដែលអ្នកបានធ្វើរួចមកហើយនៅក្នុងជីវិតរបស់អ្នក។ អ្វីៗធម្មតាដូចជា ការជួយអ្នកដទៃ ស្រឡាញ់អ្នកដទៃ បម្រើអ្នកជិតខាង ឬសហគមន៏ ធ្វើការងារល្អនៅសាលា ឬកន្លែងធ្វើការ។ ឥឡូវនេះ ចូរធ្វើបញ្ជីនៅខាងក្រោម។ ចូរក្រឡេកមើលបញ្ជីទាំងឡាយដែលអ្នកបានធ្វើ។ អ្នកទទួលអារម្មណ៏មោទនភាព និងសុភមង្គលមកពីការអាន និងអានចុះឡើងៗ នូវបញ្ជីទាំងនេះ។ អ្នកសមនឹងទទួល កុំធ្លាក់ចូលក្នុងអន្ទាក់នៃការប្រៀបធៀបបញ្ជីអ្នក ជាមួយបញ្ជីមិត្តអ្នកដែលបានសរសេរ។ បញ្ជីអ្នក គឺមានតែមួយសម្រាប់អ្នក។ គ្មាននរណាម្នាក់អាចសរសេរវាបានទេ ព្រោះវាចេញពីជីវិតរបស់អ្នកផ្ទាល់។ អ្នកជាមនុស្សពិសេសដោយឡែក។ គ្មាននរណាម្នាក់ដូចអ្នកបេះបិទតែម្តងនោះទេ។

ចូរអ្នកឆ្លុះកញ្ចក់មើលខ្លួនរបស់អ្នក ហើយនិយាយថា: “ខ្ញុំគោរពអ្នក”។ ប្រើឈ្មោះអ្នកក្នុងការធ្វើនេះ។ ឧទាហរណ៏ “ផល្លី! ខ្ញុំគោរពអ្នក” ហើយនិយាយដដែលអោយច្រើនដង។

វេជ្ជបណ្ឌិតជនជាតិអឺរ៉ុប បានជួយអតិថិជនគេ ដោយសុំឱ្យនិយាយដដែលៗពីរដងក្នុងមួយថ្ងៃថា: “រាល់ថ្ងៃតាមរបៀបណាក៏ដោយខ្ញុំកាន់តែបានប្រសើរឡើងៗ”។ សាកល្បងដូចនេះ បើអ្នកពេញចិត្តវា។ ចូរថាវាឡើងវិញប្រចាំថ្ងៃ។ វាអាចធ្វើឱ្យអ្នកស្រឡាញ់ ចូលចិត្តខ្លួនឯងបានច្រើន ហើយធ្វើឱ្យខ្លួនអ្នកផ្ទាល់បានប្រសើរថ្ងៃណាមួយ។នៅពេលដែលអ្នករៀនគោរពខ្លួនឯងច្រើនឡើងៗ អ្នកនឹងគាប់ចិត្តខ្លួនអ្នក។ ចូរសប្បាយដោយខ្លួនអ្នក នៅបច្ចុប្បន្ននេះ។ អ្នកជាមនុស្សល្អដែលគួរឱ្យស្រឡាញ់។ អ្នកមានសមត្ថភាព។ នេះជាផ្លូវត្រឹមត្រូវរបស់អ្នកហើយ។

ចូរនឹកដល់មនុស្សដែលចូលចិត្តអ្នក។ តើអ្វីដែលគេស្រឡាញ់ចូលចិត្តអ្នក? បន្ទាប់មកចូរបង្កើតបញ្ជី។ ចូររំលឹកខ្លួនអ្នក អ្វីដែលអ្នកបានធ្វើរួច អ្វីដែលអ្នកអាចធ្វើបាន ភាពប៉ិនប្រសប់ ទេពកោសល្យ អំណោយទាន ដែលអ្នកចូលចិត្ត។ ចូរចងចាំថា កុំធ្វើការប្រៀបធៀបវាទៅនឹងអំណោយទានរបស់អ្នកដទៃ។ អំណោយទានអ្នក គឺមានតែមួយជារបស់អ្នក។ អ្នកមានសមត្ថភាពជាមនុស្សគួរឱ្យស្រឡាញ់។ អ្នកដោះស្រាយបញ្ហាជីវិត និងនឹងត្រូវប្រឹងអស់ពីសមត្ថភាពក្នុងជីវិតអ្នក។ ចូរជឿជាក់បញ្ហានេះ។ និយាយប្រាប់ខ្លួនអ្នកម្តងទៀតក្នុងកញ្ចក់ថា តើអ្នកគោរពខ្លួនឯងបានប៉ុណ្ណាដូចជាសត្វមានជីវិត ដែលព្រះជាម្ចាស់បានបង្កើតមក?

ទេព ផានី


ការរិះគិតពិភាក្សាក្នុងអង្គសន្និបាត

## មហាសន្និបាតលើកទី ២១

នៅថ្ងៃទី ២០-២៣ ខែ កក្កដា ឆ្នាំ ២០០៤ នៅព្រះវិហារផ្សារទូច ព្រះសហគមន៏បានបើកអង្គសន្និបាតទូទាំងប្រទេសលើកទី ២១ មានការចូលរួមរបស់បងស្រី លោកបូជាចារ្យ និងគណៈកម្មការគ្រប់ភូមិភាគចំនួន ១១៣ នាក់ ក្រោមប្រធានបទ ”គ្រួសារសុខសាន្ត ដោយបំបាត់អំពើហិង្សា”។ អង្គការបំបាត់អំពើហិង្សាក្នុងគ្រួសារ បានបកស្រាយថា ”មិនមែនមកពីភាពក្រីក្រ ភាពអវិជ្ជា ឬសង្គ្រាមទេ ដែលធ្វើឱ្យមានអំពើហិង្សា គឺមកពីកត្តាធម្មជាតិ ”។ ក្រោយមកបានរិះគិតអំពើហិង្សាលើយុវជនវាបណ្តាលពី ”ការខកបំណង អារម្មណ៏មួម៉ៅបណ្តាលឱ្យមានអំពើហិង្សាកើតឡើង”។ នៅថ្ងៃចុងក្រោយ ពិចារណាអំពីអំពើហិង្សាទៅលើកុមារ ”តើមូលហេតុអ្វីបានជាកុមាររងនូវអំពើហិង្សាក្នុងគ្រួសារ?”។

សំអាត

messager aout 04.qxd 2/25/2005 2:19 PM Page 8

# ទេសចរណ៍

## អាងហែលទឹកដែលមានមនុស្សច្រើនក្រោមកំដៅព្រះអាទិត្យ

នាពេលថ្មីៗនេះ កំដៅព្រះអាទិត្យបានបញ្ចេញកំដៅក្តៅខ្លាំង សីតុណ្ហភាពនៅទីក្រុងហាណូយ បានឡើងដល់ ៣៨ អង្សា ជាហេតុធ្វើឱ្យប្រជាជននៅទីក្រុងនេះនាំគ្នាពពាក់ពពួនចុះត្រាំទឹកយ៉ាងច្រើនកុះករ។ ដោយឡែកអាងហែលទឹកនៅទីក្រុង Thanh Cong មានចំនួនភ្ញៀវទេសចរណ៍កើនឡើងពី ៥០០-៦០០ នាក់ ក្នុងមួយថ្ងៃ។ អាងហែលទឹកនេះមានបំពាក់គ្រឿងបរិក្ខាដូច អាងហែលទឹកអូឡាំពិក។ មានភ្ញៀវទេសចរណ៍ជិតមួយពាន់នាក់រៀងរាល់ថ្ងៃ។ នៅថ្ងៃទី ១០ តុលា ឆ្នាំ ២០០៣ មជ្ឈមណ្ឌលហែលទឹក Thai Ha និងមណ្ឌល Giang Vo ក៏មានទិដ្ឋភាពដូចគ្នានេះដែរ។ ថ្វីបើចំនួនភ្ញៀវទេសចរណ៍មានការកើនឡើងក៏ពិតមែន មានកន្លែងមួយចំនួនបានរក្សាតំលៃចូលនៅដដែល គឺ ៦០០០-១០០០០ ដុង។ មនុស្សចាស់ជរាត្រូវបានបញ្ចុះតំលៃជូន ៤០%។

## បទសំភាសន៍ជាមួយជនបរទេសអំពីវិស្សមកាល



អ្នកស្រី Aleson (រូបឆ្វេង) មកពីប្រទេសអង់គ្លេស នៅឱកាសវិស្សមកាល គាត់ចូលចិត្តការដើរកំសាន្តទៅកន្លែងឆ្ងាយ។ ក្នុងនោះគាត់បានមានប្រសាសន៍ថា "សំរាប់ជនជាតិអង់គ្លេស ចំនួលចិត្តភាគច្រើនសម្រាប់ពេលវេលាសម្រាករបស់គេ គឺទៅលេងនៅតាមឆ្នេរសមុទ្រ ដេកអាំងថ្ងៃជាដើម តែសម្រាប់ខ្ញុំគឺចូលចិត្តទិដ្ឋភាពទីក្រុង ធ្វើដំណើរឆ្ងាយៗ ដូចពេលនេះ ខ្ញុំចំណាយពេលមើលប្រាសាទនៅសៀមរាបនិងដើរលេងក្នុងក្រុងភ្នំពេញ។ ចំណែកអ្នកស្រី Helen មកពីប្រទេសញូសឺឡែន ក៏បានឱ្យយើងដឹងដែរថា " ៦ ថ្ងៃរបស់គាត់នៅ ប្រទេសកម្ពុជា បានផ្តល់នូវបទពិសោធន៍ជាច្រើនដូចជា: ទស្សនាអង្គរវត្តដ៏អស្ចារ្យ ជួបប្រជាជនខ្មែរដែលគួរឱ្យស្រលាញ់ និងបានបរិភោគម្ហូបខ្មែររួមនឹងអង្គុយដូចជនជាតិខ្មែរ ពិសេសទៅទៀតគឺអាកាសធាតុល្អ ព្រោះពេលនេះនៅញូសឺឡែន សីតុណ្ហភាពត្រជាក់ (២អង្សារ)។

មេត្រី-សំអាត

## ឆ្នេរខ្សាច់នៅទីក្រុងប៉ារីស



លោក Delanoë អភិបាលក្រុងប៉ារីស ប្រទេសបារាំង បានបង្កើតឆ្នេរខ្សាច់មាត់ទន្លេ កាត់តាមរាជធានី។ ការផ្តួចផ្តើមគំនិតនេះ ឡើងជាការឆ្លើយតបទៅនឹង"គម្រោងនៃសម្ព័ន្ធភាពសង្គម"។ ឆ្នេខ្សាច់នេះ បានរចនានិងតុបតែងឡើងយ៉ាងពិសេស សម្រាប់ប្រជាជនទីក្រុងប៉ារីសរាប់ពាន់នាក់ ដែលពុំមានលទ្ធភាពទៅវិស្សមកាលនៅទីកន្លែងឆ្ងាយៗបាន។ នៅឆ្នេរខ្សាច់មាត់ទន្លេនេះ មានដីខ្សាច់ដ៏ស្រស់ថ្លា មានដើមត្នោត កៅអីវែង និងបានអនុញ្ញាតិអោយតុបតែងនូវសកម្មភាពផ្សេងៗដោយសេរីទៀតផង។ ប៉ុន្តែ អ្វីដែលអស្ចារ្យ គឺការសាងសង់អាងទឹកដ៏ធំ ដែលមានផ្ទៃក្រឡា ២២០ ម៉ែត្រការ៉េ។ មានផ្តល់ជូនទស្សនានូវសកម្មភាពផ្សេងៗដូចជា: ការបើកបណ្ណាគារនៅលើទីវាល។

## ដំណឹងប្រលងនិពន្ធ

"អ្នកនាំសារ" សូមអញ្ជើញបងប្អូនចូលរួមប្រឡងស្នាដៃនិពន្ធ ដូចជា កំណាព្យ រឿងរ៉ាវផ្សេងៗ និងបទចម្រៀង។
សូមផ្តល់ស្នាដៃនិពន្ធរបស់លោកអ្នកមកមុនថ្ងៃ ៣១ ខែ សីហា ឆ្នាំ ២០០៤ ជាកំហិត។ អ្នកដែលមានស្នាដៃល្អ និងមានរង្វាន់លើទឹកចិត្ត ដែលមានចុះក្នុង "អ្នកនាំសារ"។
អ្នកប្រកួតប្រជែង គឺបេក្ខជនទាំងពីរភេទ ការប្រលងនេះមិនកំណត់អាយុ មុខងារ ឬប្រធានបទទេ។ សូមទាក់ទងតាមរយៈ ក. គីម សំអាត ទូរស័ព្ទលេខ ០១២ ៩១៤ ៩០២ ឬតាមអាសយដ្ឋានខាងក្រោមនេះ។

ក្រុមនិពន្ធ: គីម សំអាត
រចនាទំព័រ: ឡាង ចំនួណាង
រូបថតគ្រប: គីកេ ហ្វីការេដូ
ការិយាល័យផ្សព្វផ្សាយព័ត៌មាន
ព្រះសហគមន៍កាតូលិក: ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់បឹងប្រលិត ភ្នំពេញ
Tel/Fax: (855) 23 224 120
csc@catholiccambodia.org
អភិបាលគ្រប់គ្រង:
លោកអភិបាល អេមីល ដេតម្ប
អគ្គនាយក:
លោកបូជាចារ្យ អូមែរ ហ្សឺរ៉ាល់ដូ

Photo Xavier Huchet / D.R